ធនាគារ ប្រៃសណីយ៍កម្ពុជា
東埔寨郵政銀行 CAMBODIA POST BANK



# ព្រឹត្តិបត្រព័ត៌មាន

ខែមេសា ឆ្នាំ២០២៦ | លេខ១១



## សេដ្ឋកិច្ច និងវិស័យធនាគារនៅក្នុងប្រទេសកម្ពុជា

- កំណើនជាសកលត្រូវបានព្យាករណ៍ថានឹងធ្លាក់ចុះពី ២,៨% ក្នុងឆ្នាំ ២០២៤ មកត្រឹម ២,៣% ក្នុងឆ្នាំ ២០២៥។ ភាពតានតឹងនៃពាណិជ្ជកម្ម ភាពមិនច្បាស់លាស់នៃគោលនយោបាយ និងជម្លោះភូមិសាស្ត្រនយោបាយ បានបង្កបញ្ហាប្រឈមជាច្រើន។ បម្រែបម្រួលអាកាសធាតុ បំណុលខ្ពស់ និងថវិកាមានកំណត់ ធ្វើឱ្យប្រទេសនានាពិបាកដោះស្រាយនូវវិបត្តិ និងវិនិយោគនាពេលអនាគត។
- តំបន់អាស៊ីប៉ូស៊ីហ្វិក និងប៉ាស៊ីហ្វិក រួមទាំងប្រទេសកម្ពុជាផងដែរ ប្រឈមមុខនឹងបញ្ហាចម្បងពីរគឺ ការបង្កើតការងារកាន់តែច្រើន កាន់តែប្រសើរឡើង នឹងការដោះស្រាយជាមួយនឹងបច្ចេកវិទ្យាថ្មី ជាមួយនឹងការបង្កើនរបាំងពាណិជ្ជកម្ម។ កំណើនសេដ្ឋកិច្ចក្នុងតំបន់ត្រូវបានគេរំពឹងថានឹងធ្លាក់ចុះមកត្រឹម ៤,០%។ ប្រទេសចិននឹងកើនឡើងក្នុងអត្រា ៤,០% ខណៈពេលដែលតំបន់ផ្សេងៗនឹងកើនឡើង ៤,២% ភាគច្រើនដោយសារតែតម្រូវការពិភពលោកចុះខ្សោយ បញ្ហាវិស័យអចលនទ្រព្យដែលកំពុងបន្តនៅក្នុងប្រទេសចិន និងការកើនឡើងភាពមិនច្បាស់លាស់នៃពាណិជ្ជកម្ម។
- សេដ្ឋកិច្ចរបស់កម្ពុជាកំពុងប្រឈមមុខនឹងបញ្ហាជាច្រើនក្នុងពេលដំណាលគ្នារួមមាន ការធ្លាក់ចុះរយៈពេលវែងនៃវិស័យអចលនទ្រព្យ ជម្លោះព្រំដែនដែលកំពុងតែបន្ត និងការប្រែប្រួលនៃការនាំចេញ ដោយសារការដំឡើងពន្ធ និងការធ្លាក់ចុះនៃតម្លៃអង្ករ។
- បញ្ហាប្រឈមក្នុងវិស័យអចលនវត្ថុបាននាំឱ្យមានការធ្លាក់ចុះយ៉ាងខ្លាំង ចំពោះការវិនិយោគអចលនទ្រព្យ។
- ជម្លោះព្រំដែនបានធ្វើឱ្យសេដ្ឋកិច្ចកម្ពុជាកាន់តែតានតឹង ដោយការផ្ញើរប្រាក់ពីក្រៅប្រទេសមានការចុះថយ ខណៈការវិលត្រឡប់របស់ពលករចំណាកស្រុកជិត ១លាននាក់បានបន្ថែមជាសម្ពាធដល់ទីផ្សារការងារកម្ពុជា ដែលកំពុងនៅខ្សោយស្រាប់។
- ការនាំចេញ ដែលពីមុនជាសសរស្តម្ភនៃភាពធន់របស់សេដ្ឋកិច្ចកម្ពុជា ឥឡូវកំពុងប្រឈមនឹងហានិភ័យថ្មី ដោយសារភាពមិនប្រាកដប្រជានៃគោលនយោបាយពាណិជ្ជកម្មពិភពលោក ខណៈដែលការធ្លាក់ចុះតម្លៃស្រូវបានប៉ះពាល់មួយភាគបីនៃកម្លាំងពលកម្មទាំងអស់។

## Real GDP growth Moderated




## Muted Property Investment Appetite




## Declining Remittances




## Job Opportunities from QIPs




- កំណើន GDP របស់កម្ពុជាត្រូវបានប៉ាន់ប្រមាណថាមាន ៤,៨% នៅក្នុងឆ្នាំ ២០២៥ និងបានព្យាករណ៍ថានឹងថយចុះមកត្រឹម ៤,៣% នៅក្នុងឆ្នាំ ២០២៦ និងកើនឡើងវិញដល់ ៥,១% នៅឆ្នាំ ២០២៧។
- ឆ្នាំ២០២៥ មានភាពប្រសើរឡើងវិញ ដោយសារតែការនាំចេញផលិតផលសម្លៀកបំពាក់ ស្បែកជើង និងទំនិញធ្វើដំណើរ (GTF) កាលពីដើមឆ្នាំ ខណៈពេលឆ្នាំ២០២៦ ត្រូវបានរំពឹងទុកថានឹងមានកំណើនយឺត ដោយសារតែការចំណាយក្នុងគ្រួសារ និងអាជីវកម្មនានាមិនទាន់ល្អប្រសើរពេញលេញនៅឡើយ។
- ក្នុងរយៈពេលខ្លី ការត្រឡប់មកវិញនៃពលករចំណាកស្រុកមកកាន់កម្ពុជា អាចប៉ះពាល់ដល់ទីផ្សារការងារ និងសេវាសង្គមនានា។ ប៉ុន្តែការវិលត្រឡប់នេះ ក៏នឹងនាំមកវិញនូវ ជំនាញ និងកម្លាំងពលកម្ម សម្រាប់ផលិតភាព និងកំណើនសេដ្ឋកិច្ចរបស់កម្ពុជាផងដែរ។
- ក្នុងរយៈពេលវែង ដោយសារពាណិជ្ជកម្ម និងភស្តុភារមានភាពប្រសើរ កម្ពុជានឹងអាចឆ្លើយតបនឹងតម្រូវការដែលកំពុងកើនឡើង ដោយសារការត្រឡប់មកវិញរបស់ពលករចំណាកស្រុក។ ការវិនិយោគលើការដឹកជញ្ជូន ជាពិសេសកំពង់ផែ និងផ្លូវហាយវេ ត្រូវបានគេរំពឹងថានឹងជួយជំរុញសេដ្ឋកិច្ចផងដែរ។
- ប៉ុន្តែ នៅពេលប្រទេសកម្ពុជាវិវឌ្ឍខ្លួនពីប្រទេសមានការអភិវឌ្ឍន៍តិចតួចបំផុតនៅឆ្នាំ២០២៩ កម្ពុជាអាចនឹងប្រឈមជាមួយការកាត់បន្ថយជំនួយសម្បទានអភិវឌ្ឍន៍ផ្លូវការ (ODA) និងអត្ថប្រយោជន៍ពាណិជ្ជកម្មមួយចំនួន ទៅតាមលក្ខខណ្ឌអន្តរកាល និងគោលនយោបាយដៃគូ។
- នៅក្នុងប្រទេស ការកើនឡើងសម្ពាធទីផ្សារការងារ និងការកើនឡើងនៃឥណទានមិនដំណើរការ (NPLs) អាចប៉ះពាល់ដល់សកម្មភាពសេដ្ឋកិច្ច។

- លើសពីនេះ សង្គ្រាមព្រំដែនអាចកើតមានសារជាថ្មី ដែលអាចបង្កហានិភ័យបន្ថែមទៀត។ ដោយឡែក តម្រូវការសកលដែលខ្សោយជាងមុន ដោយសារការផ្លាស់ប្តូរគោលនយោបាយពាណិជ្ជកម្ម និងការងើបឡើងវិញយឺតជាងការរំពឹងទុកនៅក្នុងប្រទេសចិន ដែលជាប្រភពចម្បងនៃការវិនិយោគផ្ទាល់ពីបរទេស និងទេសចរណ៍របស់កម្ពុជា នឹងដាក់សម្ពាធបន្ថែមលើសេដ្ឋកិច្ចកម្ពុជា។

## The current account deficit widened




## Increasing FDI, led by China




## Rising FDI in manufacturing




## Deposits boosted broad money




សហរដ្ឋអាមេរិក និងអ៊ីស្រាអែលបានចាប់ផ្តើមប្រតិបត្តិការ “Epic Fury” នៅថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ ២០២៦ ជាមួយនឹងការវាយប្រហារតាមផ្លូវអាកាស និងការវាយប្រហារដោយមីស៊ីលទៅលើទីតាំងយុទ្ធសាស្ត្រយោធាអ៊ីរ៉ង់ រួមមានកន្លែងផ្ទុកនុយក្លេអ៊ែរ និងមូលដ្ឋានផ្កាំបដិវត្តន៍។ ការវាយប្រហារដោយប្រើប្រាស់មីនសមុទ្រ និងការវាយប្រហារនាវាដឹកប្រេង បានរំខានដល់ការដឹកប្រេងតាមច្រកសមុទ្រ Hormuz ដែលប្រេងប្រមាណ២០% និងឧស្ម័នLPG ប្រមាណ២៥% របស់ពិភពលោក ត្រូវបានដឹកជញ្ជូនឆ្លងកាត់ច្រកសមុទ្រអន្តរជាតិមួយនេះ ។ តម្លៃប្រេងឆៅ បានកើនឡើងដល់ ៨២ដុល្លារក្នុងមួយបារ៉ែលនៅថ្ងៃទី២ ខែមីនា ឆ្នាំ២០២៦ ដែលជាការកើនឡើង ១៥%ក្នុងរយៈពេល ៤៨ម៉ោង។ ផលប៉ះពាល់បានមកដល់ប្រទេសកម្ពុជាក្នុងរយៈពេលតែប៉ុន្មានថ្ងៃប៉ុណ្ណោះពីព្រោះកម្ពុជា ជាប្រទេសដែលគ្មានធនធានប្រេង និងពឹងផ្អែកទាំងស្រុងលើការនាំចូលប្រេង តាមរយៈរោងចក្រចម្រាញ់ប្រេងសឹង្ហបុរី និងកំពង់ផែក្រុងព្រះសីហនុ។

តម្លៃប្រេងឥន្ធនៈ ដែលកំណត់ដោយក្រសួងពាណិជ្ជកម្មប្រចាំសប្តាហ៍ គឺជាការកើនឡើងខ្លាំងបំផុតចាប់តាំងពីឆ្នាំ២០២២។ ការបិទផ្នែកខ្លះនៃច្រកសមុទ្រ Hormuz រួមជាមួយនឹងការវាយប្រហារលើនាវា និងការរំពឹងទុកទីផ្សារ បានបង្កើនការព្រួយបារម្ភ បើទោះបីជាកម្ពុជាមានប្រេងបម្រុងទុក ប្រហែល 300,000 តោន ដែលអាចប្រើប្រាស់បានរយៈពេលប្រហែលមួយខែក៏ដោយ ។

៧០%នៃប្រជាជនកម្ពុជា បានចំណាយលើសពី២០%នៃប្រាក់ចំណូលរបស់ពួកគេ ទៅលើការដឹកជញ្ជូន និងថាមពល ដែលនាំឱ្យអតិផរណានាំចូលកាន់តែខ្ពស់។ នៅរាជធានីភ្នំពេញ តម្លៃនៃការធ្វើដំណើរតាមតុកតុក និងតាក់ស៊ី បានកើនឡើងប្រហែល២០% រីឯតម្លៃម្ហូបអាហារក៏បានកើនឡើងដោយសារថ្លៃដឹកជញ្ជូនក៏កើនឡើងដែរ។ វិស័យទេសចរណ៍ (ភ្ញៀវទេសចរណ៍ប្រមាណ៧លាននាក់ក្នុងមួយឆ្នាំ) និងឧស្សាហកម្មកាត់ដេរនៅកម្ពុជា (៨០%នៃការនាំចេញ) រងផលប៉ះពាល់ខ្លាំងជាងគេ។

លើសពីការកើនឡើងនៃតម្លៃប្រេងឥន្ធនៈ វិបត្តិនេះក៏នឹងបង្កើនហានិភ័យសេដ្ឋកិច្ចផងដែរ។ អតិផរណាថាមពលអាចឡើងដល់៥-៧%ប្រសិនបើតម្លៃប្រេងឆៅនៅបន្តលើសពី ៨០ ដុល្លារក្នុងមួយបារ៉ែល ដែលនេះនឹងប៉ះពាល់ដល់កម្មករដែលមានចំណូលទាប ប្រហែល៥លាននាក់ និងបង្កើតសម្ពាធដល់តំបន់ជនបទ។ ការនាំចេញអង្ករ និងកៅស៊ូអាចប្រឈមនឹងតម្លៃដឹកជញ្ជូនខ្ពស់ជាងមុនប្រមាណ១០-១៥%។ ដើម្បីឆ្លើយតបនឹងបញ្ហាប្រឈមនេះ រាជរដ្ឋាភិបាលបានប្រកាសឧបត្ថម្ភថវិការរដ្ឋដល់ការដឹកជញ្ជូន និងរថយន្តក្រុងសាធារណៈ ដើម្បីសម្រួលថ្លៃធ្វើដំណើរ។

សេដ្ឋវិទូ និងអង្គការក្រៅរដ្ឋាភិបាលអំពាវនាវឱ្យរាជរដ្ឋាភិបាល បង្កើនអ្នកផ្គត់ផ្គង់ប្រេងឱ្យបានច្រើន (ពីរុស្ស៊ី និងអូស្ត្រាលី) បង្កើនការប្រើប្រាស់ថាមពលកកើតឡើងវិញ (ឱ្យបាន២០% នៅឆ្នាំ២០៣០) និងពង្រឹងសំណាញ់សុវត្ថិភាព បើមិនដូច្នេះទេប្រជាជន ១លាននាក់ទៀតអាចធ្លាក់ចូលទៅក្នុងភាពក្រីក្របំផុត។

*Source: Cambodia Economic Update Dec.25, The World Bank;*
*Cambodia investment Revie; Cambodgmag news dated March 11, 2026*





ធនាគារ ប្រៃសណីយ៍កម្ពុជា
東埔寨郵政銀行 CAMBODIA POST BANK

ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី
富南小額信貸公司 FUNAN Microfinance Plc.

# មហាសន្និបាតប្រចាំឆ្នាំលើកទី១២

## 12th General Assembly

ថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៦ | សណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ

ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំមហាសន្និបាតប្រចាំឆ្នាំលើកទី១២ ដែលបានប្រារព្ធឡើងនៅសណ្ឋាគារឯករាជ្យ ខេត្តព្រះសីហនុ នាថ្ងៃសៅរ៍ ទី១៧ ខែមករា ឆ្នាំ២០២៦ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់លោក **តូច ចៅចេក** ប្រធាននាយកប្រតិបត្តិ និងមានការចូលរួមពីគណៈគ្រប់គ្រងជាន់ខ្ពស់ នាយក នាយិកាទូទាំងប្រទេស។

មហាសន្និបាតនេះ ប្រារព្ធឡើងក្រោមគោលបំណងបូកសរុបលទ្ធផលការងារដែលសម្រេចបានក្នុងឆ្នាំ២០២៥ និងការកំណត់ផែនការយុទ្ធសាស្ត្រសម្រាប់ឆ្នាំ២០២៦។














មហាសន្និបាតនេះក៏បានផ្ដល់ឱកាសដល់គណៈគ្រប់គ្រងទាំងអស់ក្នុងការពង្រឹងទំនាក់ទំនង និងកិច្ចសហការគ្នាដើម្បីបង្កើនគុណភាពនៃការគ្រប់គ្រងការងារឱ្យមានប្រសិទ្ធភាពខ្ពស់ ជាពិសេសការកំណត់ផែនការយុទ្ធសាស្ត្រធ្វើយ៉ាងណាឱ្យអតិថិជនទទួលបានការផ្ដល់សេវាហិរញ្ញវត្ថុល្អបំផុត។

លើសពីនេះ គណៈគ្រប់គ្រង ក៏បានប្រគល់វិញ្ញាបនបត្រសរសើរជូនសាខាឆ្នើម ប្រចាំឆ្នាំ២០២៥ សម្រាប់កិច្ចខិតខំប្រឹងប្រែងក្នុងការសម្រេចបាននូវសមិទ្ធផលការងារបានយ៉ាងល្អប្រសើរ ផងដែរ។











## ធនាគារ ប្រៃសណីយ៍កម្ពុជា ឧបត្ថម្ភកិច្ចប្រជុំប្រចាំឆ្នាំ២០២៥ របស់សភាពាណិជ្ជកម្ពុជា







ធនាគារ ប្រៃសណីយ៍កម្ពុជា មានមោទនភាពដែលបានចូលរួមជា **Silver Sponsor** ក្នុង **“កិច្ចប្រជុំប្រចាំឆ្នាំ ២០២៥ និងទិសដៅការងារ ២០២៦”** របស់សភាពាណិជ្ជកម្មកម្ពុជា។

ការចូលរួមនេះសរបញ្ជាក់ពីការប្តេជ្ញាចិត្តរបស់ធនាគារ ក្នុងការជំរុញ និងគាំទ្រដល់ការអភិវឌ្ឍវិស័យធុរកិច្ច ក៏ដូចជាពាណិជ្ជកម្មក្នុងស្រុកឱ្យកាន់តែរឹងមាំ និងមាននិរន្តរភាព។

## ធនាគារ ប្រៃសណីយ៍កម្ពុជា ទទួលវិញ្ញាបនបត្រ SWIFT Customer Security Controls Framework



ធនាគារ ប្រៃសណីយ៍កម្ពុជា ទទួលបានវិញ្ញាបនបត្រអនុលោមភាពសម្រាប់ក្របខ័ណ្ឌត្រួតពិនិត្យសន្តិសុខអតិថិជនប្រើសេវាផ្ទេរប្រាក់ក្រៅប្រទេសតាមប្រព័ន្ធ SWIFT (SWIFT Customer Security Controls Framework v2025)។

វិញ្ញាបនបត្រដ៏វិសេសនេះត្រូវបានវាយតម្លៃ និងប្រគល់ជូនដោយក្រុមហ៊ុន SISA Information Security Worldwide នៅថ្ងៃទី២២ ខែមករា ឆ្នាំ ២០២៦ នៅស្នាក់ការកណ្តាលរបស់ធនាគារប្រៃសណីយ៍កម្ពុជា បន្ទាប់ពីឆ្លងកាត់ដំណើរការវាយតម្លៃយ៉ាងហ្មត់ចត់ និងឯករាជ្យដោយផ្អែកលើភស្តុតាង និងឯកសារនានា។

សមិទ្ធផលដ៏សំខាន់នេះសបញ្ជាក់ពីការយកចិត្តទុកដាក់ និងភាពល្អប្រសើររបស់ធនាគារប្រៃសណីយ៍កម្ពុជា ក្នុងការការពារព័ត៌មានសំខាន់ៗរបស់អតិថិជន ទន្ទឹមនឹងការរក្សាបាននូវបទដ្ឋានសុវត្ថិភាពខ្ពស់បំផុតជាសកល។

ធនាគារ ប្រៃសណីយ៍កម្ពុជា នៅតែប្តេជ្ញាចិត្តខ្ពស់ក្នុងការធានាថាព័ត៌មាន និងប្រតិបត្តិការរបស់អតិថិជនត្រូវបានការពារ និងមានសុវត្ថិភាព។ ធនាគារបន្តពង្រឹងផ្នែកបច្ចេកវិទ្យា និងវិធានការសុវត្ថិភាព ដើម្បីធានាថាការផ្ទេរប្រាក់អន្តរជាតិមានសុវត្ថិភាព និងងាយស្រួលសម្រាប់អតិថិជនទាំងអស់។

# ធនាគារ ប្រៃសណីយ៍កម្ពុជា រៀបចំកិច្ចប្រជុំនាយក-នាយិកាសាខានៅកសិដ្ឋាន អមរៈ



នៅថ្ងៃទី០៧ ខែកុម្ភៈ ឆ្នាំ២០២៦ ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកិច្ចប្រជុំនាយក-នាយិកាសាខានៅកសិដ្ឋាន អមរៈ ដើម្បីត្រួតពិនិត្យលទ្ធផលការងារ និងកំណត់ផែនការសកម្មភាពសម្រាប់ខែបន្ទាប់។













# ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមក្នុងកម្មវិធីជួបជុំមហាគ្រួសារកាណាឌីយ៉ា





នៅថ្ងៃទី៧ ខែកុម្ភៈ ឆ្នាំ២០២៦ ថ្នាក់ដឹកនាំ និងបុគ្គលិកនៃធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួមយ៉ាងផុសផុលនៅក្នុងកម្មវិធីជួបជុំសំណេះសំណាលបុគ្គលិកមហាគ្រួសារកាណាឌីយ៉ា។ កម្មវិធីនេះគឺជាវេទិកាដ៏មានអត្ថន័យ និងសំខាន់បំផុត ដែលអនុញ្ញាតឱ្យគណៈគ្រប់គ្រង និងបុគ្គលិកគ្រប់ជាន់ថ្នាក់បានជួបជុំ ដើម្បីពង្រឹងស្មារតីសាមគ្គីភាព និងឯកភាពជាតិជាធ្លុងមួយ ព្រមទាំងបានស្តាប់នូវទិសដៅ និងយុទ្ធសាស្ត្រសម្រាប់ឆ្នាំខាងមុខដោយផ្ទាល់ពីថ្នាក់ដឹកនាំកំពូល។

កម្មវិធីនេះបានប្រព្រឹត្តទៅក្រោមវត្តមានដ៏ខ្ពង់ខ្ពស់របស់ លោកអ្នកឧកញ៉ាបណ្ឌិត **ពុង ឃាវសែ** ប្រធានក្រុមប្រឹក្សាភិបាលនៃក្រុមហ៊ុនកាណាឌីយ៉ាគ្រុប, លោកស្រីវេជ្ជបណ្ឌិត **Carolyne Pung** អនុប្រធានក្រុមប្រឹក្សាភិបាល។







# ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលជួបសម្តែងការគួរសម លោកអ្នកឧកញ៉ា ប្រធានក្រុមប្រឹក្សាភិបាលក្នុងឱកាសពិធីបុណ្យចូលឆ្នាំចិន






នៅរសៀលថ្ងៃទី១២ ខែកុម្ភៈ ឆ្នាំ២០២៦ ថ្នាក់ដឹកនាំជាន់ខ្ពស់នៃ ធនាគារ ប្រៃសណីយ៍កម្ពុជា និង ហ្វូណន មីក្រូហិរញ្ញវត្ថុ ភីអិលស៊ី បាន ទទួលការអនុញ្ញាតដ៏ខ្ពង់ខ្ពស់ពី លោកអ្នកឧកញ៉ាបណ្ឌិត **ពុង ឃាវសែ** ប្រធានក្រុមប្រឹក្សាភិបាល និង លោកស្រីវេជ្ជបណ្ឌិត **Carolyne Pung** អនុប្រធានក្រុមប្រឹក្សាភិបាល នៃធនាគារ ប្រៃសណីយ៍កម្ពុជា ក្នុងការចូលជួបសម្តែងការគួរសម និងនាំយកនូវកន្ត្រកក្រូចអនុស្សាវរីយ៍ តំណាងឱ្យសេចក្តីសុខរុងរឿងចំរុងចម្រើនចូលជូនពរ ក្នុងឱកាសអបអរសាទរ ពិធីបុណ្យចូលឆ្នាំថ្មី ប្រពៃណីចិន (ឆ្នាំមមី)។

ក្នុងឱកាសដ៏វិសេសវិសាលនេះ តំណាងថ្នាក់ដឹកនាំ និងបុគ្គលិកទាំងអស់ សូមសម្តែងនូវការគោរពដឹងគុណយ៉ាងជ្រាលជ្រៅ និងសូមបួងសួងដល់ទេវតាឆ្នាំថ្មី សូមតាមជួយបីបាច់ថែរក្សា លោកអ្នកឧកញ៉ាបណ្ឌិត និង លោកស្រីវេជ្ជបណ្ឌិត ព្រមទាំងក្រុមគ្រួសារ សូមប្រកបដោយសុខភាពល្អបរិបូរណ៍ កម្លាំងពលំមាំមួន បញ្ញាញាណភ្លឺថ្លា អាយុយឺនយូរ និងទទួលបានជោគជ័យគ្រប់ភារកិច្ច ដើម្បីបន្តដឹកនាំធនាគារ ប្រៃសណីយ៍កម្ពុជាឱ្យកាន់តែរីកចម្រើនរុងរឿងជានិច្ចនិរន្តរ៍តរៀងទៅ។





# ធនាគារ ប្រៃសណីយ៍កម្ពុជា ចូលរួមក្នុងកម្មវិធី អបអរទិវាអន្តរជាតិនារី និងទិវារត់ប្រណាំងស្ត្រីចម្ងាយ ១០គីឡូម៉ែត្រ



ធនាគារ ប្រៃសណីយ៍កម្ពុជា បានចូលរួមក្នុងកម្មវិធី អបអរទិវាអន្តរជាតិនារី និងទិវារត់ប្រណាំងស្ត្រីចម្ងាយ ១០គីឡូម៉ែត្រ ដែលប្រព្រឹត្តឡើង នៅថ្ងៃទី៨ ខែមីនា ឆ្នាំ២០២៦ នៅសួនច្បារខាងមុខវត្តបទុមវត្តី។

ទិវារត់ប្រណាំងស្ត្រីចម្ងាយ ១០គីឡូម៉ែត្រ ត្រូវបានរៀបចំឡើងក្នុងគោលបំណងអបអរទិវាអន្តរជាតិនារី ៨ មីនា ក្រោមប្រធានបទ **“ស្ត្រីរត់លើវិថីសន្តិភាព”**។









# ធនាគារ ប្រៃសណីយ៍កម្ពុជា ឧបត្ថម្ភធំ ក្នុងការរៀបចំកម្មវិធីនានាប្រចាំឆ្នាំ២០២៦ របស់សភាពាណិជ្ជកម្មកម្ពុជា

ធនាគារ ប្រៃសណីយ៍កម្ពុជា ពិតជាមានកិត្តិយស និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដែលបានចូលរួមជា អ្នកឧបត្ថម្ភធំ (Diamond Sponsor) ក្នុងការរៀបចំកម្មវិធីនានាប្រចាំឆ្នាំ២០២៦ (CCC’s Annual Event 2026) របស់សភាពាណិជ្ជកម្មកម្ពុជា។



ទន្ទឹមនឹងភាពជាដៃគូនេះ ធនាគារ ប្រៃសណីយ៍កម្ពុជា ក៏ទទួលបាន «លិខិតថ្លែងអំណរគុណ» ពីសភាពាណិជ្ជកម្មកម្ពុជា ក្នុងឱកាសនៃការចូលរួមសិក្ខាសាលាស្តីពី «អនុលោមភាពភូតគាមអនាម័យ និងវិញ្ញាបនបត្របញ្ជាក់ប្រភពដើមទំនិញសម្រាប់ការនាំចេញ» កាលពីថ្ងៃទី១១ ខែមីនា ឆ្នាំ២០២៦ កន្លងទៅនេះផងដែរ។

# ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកម្មវិធីប្រកួតពានរង្វាន់បាល់ទាត់ធនាគារ ឆ្នាំ២០២៦




ធនាគារ ប្រៃសណីយ៍កម្ពុជា បានរៀបចំកម្មវិធីប្រកួតពានរង្វាន់បាល់ទាត់ធនាគារ ឆ្នាំ២០២៦ ដើម្បីពង្រឹងចំណងមិត្តភាព សាមគ្គីភាព និងទំនាក់ទំនងរវាងបុគ្គលិកទាំងអស់តាមរយៈកីឡា។

ពិធីបើកការប្រកួតពានរង្វាន់បាល់ទាត់នេះ បានប្រារព្ធឡើងនាល្ងាចថ្ងៃសុក្រ ទី១៣ ខែមីនា ឆ្នាំ២០២៦ នៅទីលានបាល់ទាត់ T-Soccer ដោយមានការចូលរួមដោយលោក **តូច ចៅចេក** ប្រធាននាយកប្រតិបត្តិធនាគារ ប្រៃសណីយ៍កម្ពុជា និងតំណាងក្រុមកីឡាករទាំង ៦៤ក្រុម ដែលមកពីសាខាទាំង ៦៤ របស់ធនាគារ ប្រៃសណីយ៍កម្ពុជា។

គួរបញ្ជាក់ផងដែរថា ក្នុងការប្រកួតដណ្តើមពានរង្វាន់នេះ កីឡាករត្រូវបែងចែកជា ១៦ពូល ដោយក្នុង ១ពូល មាន៤ក្រុម។

ក្រុមនីមួយៗត្រូវប្រកួតសន្សំពិន្ទុនៅក្នុងពូល ដោយអ្នកឈ្នះត្រូវបន្តប្រកួតក្នុងវគ្គចម្រុះ រហូតដល់វគ្គផ្តាច់ព្រ័ត្រ ដោយជ្រើសរើសក្រុមជើងឯកលេខ១ លេខ២ លេខ៣ និងលេខ៤។















# រូបភាពអនុស្សាវរីយ៍ខ្លះៗ របស់ក្រុម CPBank ក្នុងជំនួបមិត្តភាពជាមួយក្រុម TrueVISIONS
# កាលពីល្ងាច ថ្ងៃទី ២៦ ខែ មីនា ឆ្នាំ២០២៦



























# តម្រូវការឥណទានបន្ទាន់មែនទេ?

# អាចស្នើសុំ ឥណទាន Nano ពី CPBank បាន

អាចខ្ចីបានរហូតដល់

**$1,000**

- ស្នើតាម CPBank App
- អនុម័តដោយស្វ័យប្រវត្តិ
- ទទួលបានប្រាក់ភ្លាមៗ




[លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត]


ទិញទំនិញផ្សេងៗ ជាមួយឥណទាន
CPBank Buy Now Pay Later
0%
គ្មានការប្រាក់
MacBook Air
Mockup
13:13
*លក្ខខណ្ឌផ្សេងៗត្រូវបានអនុវត្ត